អាក.....អ្ហាក.....

សម្រែកនេះខ្សោយទៅៗនិងរលត់ឈឹងទៅក្នុងអន្ធការ ក្លាយជាដង្ហើមចុងក្រោយនៃសុភមង្គលរបស់ក្រុមនិស្សិតដែលទើបនឹងបានទទួលបរិញ្ញាបត្រ។

«ម៉ាលី? ម៉ាលី?»

ពួកគេស្រែកហៅនាង ប៉ុន្តែសល់តែសំឡេងស្លឹកឈើទង្គិចនិងរាំយោរាត្រីគ្មានអ្វីក្រៅពីនោះទៀតឡើយ។ មុនពេលពិភពលោកមួយនេះប្តូរទៅជាងងឹតសូន្យសុង មិត្តរបស់នាងងឿងឆ្ងល់ថា តើនាងទៅណាយូរម្ល៉េះ? សុម៉ាលីជានិស្សិតគណនេយ្យដែលមានភាពអន់អាក់ ស្ទាក់ស្ទើរក្នុងការនិយាយស្តី ហើយនេះជាដំណើរបោះជំរំលើកដំបូងរបស់នាង។

នាងជានារីចម្លែក ដែលមានរសជាតិនិងជីវជាតិដូចផ្លែក្រូច តែមើលពីក្រៅខ្ចិលហូបព្រោះសម្បកហាក់ហាងនិងហឹរ។ នាងមិនមានមិត្តច្រើន តែក៏គ្មានអ្នកច្រណែននាងដែរ ចុះហេតុអ្វីនៅពេលដែលការឈឺចាប់ស្រន់ទៅៗ ហើយមានអារម្មណ៍ថារបួសបានសម្លាប់នាងជាង៩០ភាគរយនៃអាយុជីវិតទាំងអស់ទៅហើយ នាងខំត្រដរសរសេរអ្វីម្យ៉ាងទៅលើដី។ បាតជើងមនុស្សអាវខ្មៅដ៏អប្រិយ បានលូកមកជាន់កម្ទេចគំនូរនាង។ នាងទ្រាំសំងំចង់នៅរស់ឱ្យបានយូរជាងនេះបន្តិចទៅទៀត ទម្រាំវាចាកចេញ នាងដឹងថាគួរផ្តល់ដំណឹងបែបណានៅពេលប៉ូលិសមកដល់ តែចុងក្រោយជនកំណាចមិនលែងជើងចេញពីដៃនាងទេ។ នាងឈឺហើយស្រែក តែមាត់អស់ខ្យល់សម្រាប់ស្រែក ប្រតិកម្មនាងពីកចុះក្រោមបាត់លែងទាក់ទងបាន សាកលលោកមិនខ្វល់ពីបេះដូងនាងថា កំពុងលែងកន្ត្រាក់ទេ នាងនៅឮមិត្តនាងស្រែកហៅពីឆ្ងាយ ហើយឆ្ងាយឡើងៗ.....

ព្រះនៅឯណា តើទ្រង់នឹងសង្គ្រោះមនុស្សស្រីម្នាក់ដូចនាងទេ? អត់ទេ ដង្ហើមចុងក្រោយបានមកដល់...នាងត្រូវការវាណាស់ វាខ្វះខ្លាំងណាស់ នាងបានត្រដរខ្យល់ ហើយរាងកាយនាងកន្ត្រាក់ផ្តាច់ខ្លួនពីលំហអាកាសខ្យល់អុកស៊ីសែនលែងចេញចូលបានទៀតហើយ....ថ្ងៃនេះឆ្នាំក្រោយ មិត្តនាងទាំង៥និងនឹកដល់នាងយ៉ាងក្រៀមក្រំ....

នេះជារដូវរំហើយ។ មេឃនិងអាកាសធាតុ ល្អឥតខ្ចោះតែម្តងសម្រាប់វិស្សមកាល។

ភិនដាស្រែកឡើងរអ៊ូតិចៗបញ្ចោក់ពីក្តីសៅហ្មង៖

«ប្រាប់ហើយថា មិនចង់មក! ប្រាប់មិនស្តាប់ ឥឡូវមានរឿងមែន!»

ឌីនយល់ចិត្តសង្សារ ចំណុចក្រហមនេះជាជំរំមួយដែលគ្រូនាងម្នាក់ឈ្មោះធីម កាលពីប្រមាណជាង៤ឆ្នាំមុនធ្លាប់បាត់បានខ្លួន ក្រោមកាលៈទេសៈចម្លែក។ ប៉ូលិសរកមិនឃើញសូម្បីតែសព។ នេះជាករណីបាត់ខ្លួនដ៏អាថ៌កំបាំងមួយមកទល់ពេលនេះ។

«ម៉ាក់ កូនចង់ទៅផ្ទះវិញ!» នាងរអ៊ូតិចៗងរង៉ក់តាមចរិតជាកូនពៅដែលអីបន្តិចស្រែករកម្ដាយ ធ្វើឱ្យឌីនរឹតតែក្នាញ់តាមលួងស្រី។

«អ្ហូយកូនក្មេង! ឈប់ងរមើល៍ កុំម៉ែរឿងធូន់ធូរពេក ម៉ាលីអាចថាទៅសំងំនិយាយទូរសព្ទនៅឯណាផងក៏មិនដឹង?!»

«ចុះឯណាទៅហ៊ាងនិងGen?»

«ហ៊ាងនិងGenចេញទៅតាមផ្លូវរទេះ! យើងទៅរកពួកគេនៅខ្ទមឧសដែលយើងជួបអ្នកលក់ឧសកាលពីព្រលប់ទៅ!»

ឌីនបបួលបែបនេះ ភិនដាក៏យល់ព្រមបង្វែរទិសដៅតាមសម្ដីសង្សារ។ ជាមួយពិលធំមួយក្នុងដៃតាមពិតពន្លឺពិតជាគ្រប់គ្រាន់មិនមានអ្វីត្រូវភ័យព្រួយទេ ណាមួយពួកគេកំពុងបកទៅខ្ទមលក់ឧស គឺបកទៅភូមិវិញមិនមែនចូលព្រៃឡើយ។

យុវវ័យក្រុមនេះមកលេងតំបន់ Camping ចំណុចក្រហមដ៏ល្បីជាមួយគ្នាដល់ទៅ៨នាក់គឺ ម៉ាលី ពេជ្រ Gen ហ៊ាង នីននិងវុធ ភិនដានិងឌីន។ ពួកគេសុទ្ធសឹងតែជាគូស្នេហ៍ លើកលែងតែពេជ្រនិងម៉ាលី មិនដឹងថាតើពួកគេយល់ចិត្តគ្នាឬនៅឡើយទេ ប៉ុន្តែពីរនាក់នេះគ្មានគូមកជាមួយទេ។

«ទូរសព្ទអត់សេវាសោះ រាល់ដងចំណុចក្រហមនេះមិនដែលបែបហ្នឹងទេឌីន គឺមានសេវាធម្មតា!» នាងនិយាយឡើងទាំងធ្វើភ្នែកស្លើតស្លក់។ ភិនដាដូចជាភ័យខ្លាំងណាស់ សឹងថាការភ័យរបស់នាង អាចបំភ័យដោយទាំងសង្សារខ្លួនទៀត។

ឌីនឆ្លៀតពេលឈ្លីសក់ស្រីស្នេហ៍និងលួងលោម។

«កុំភ័យពេកកូនក្មេង! ជួនកាលម៉ាលីនិងពេជ្រគេឆ្លៀតទៅសាសងគ្នាឯណាផងមិនដឹង!»

«មានហ្នាំ ឃើញពេជ្រទើបតែចេញទៅហ្នឹង! គេក៏រកម៉ាលីដែរ!» ភិនដានិយាយ។

«អឺ...នីនទៅជាមួយវុធ! Genទៅជាមួយហ៊ាង ចុះពេជ្រទៅជាមួយអ្នកណា?!» ឌីនសួរដោយក្រពាត់ឆ្ងាក់កាន់ម្រាមទាំងប្រាំរបស់ភិនដា។ ស្រីស្នេហ៍ធ្វើមុខស្រពោននិយាយតបសង្សារ៖

«គ្នាគ្មានគូនឹងគេ បានជាទៅម្នាក់ឯងហ្នឹងណ៎! ហេតុអីមិនដើរជាមួយពួកយើងហ្ន៎? អីពេជ្រ...ៗ នៅក្បែរៗនេះអត់?!»

«តែបេះដូងគេប្រហែលជាមានគូហើយ! គេមិនឯកោទេកុំបាច់ហៅគេមើល៍ គេមិនចង់រំខាន់យើងហ្នឹងណា៎!»

ថាហើយ នាយក៏ទាញសង្សារមកឱបរឹតកណ្ដាលព្រៃក្រោមស្បៃមេឃងងឹតសុងសូន្យ។ ពន្លឺពិលបាញ់ទៅលើដីវិញ ទុកឱ្យភិនដាច្រានឌីនចេញគេចមិនឱ្យគេថើប។

«កុំធ្វើអីចឹងឌីន! ដាគ្មានអារម្មណ៍ទេ ទៅរកគ្នាយើងសិនទៅ! យូរទៅៗហៅគ្នាលែងឮហើយនៀក! នីននិងវុធក៏មិនឃើញ»

ឌីនខ្សឹបមិនលែងនាងសោះ៖

«គេចង់ដើរបែកកូនក្មេង នឹងបានទៅលបធ្វើរឿងស្វីតៗជាមួយគ្នាគេដឹង? ស្រែកហៅគេធ្វើអី? ធ្វើដូចមិនដឹងម៉េចទេស!»

នាងវាយទ្រូងគេដែលមិនភ័យព្រួយរឿងបាត់មិត្ត បែរជាមកងងើលដុតរោលនិយាយតែរឿងស្នេហា។ ភិនដាមិនចង់និយាយតវ៉ាទេ ក្នុងចិត្តនាងដឹងថា គ្រប់គ្នាមានគូ សុទ្ធតែបានគេងតង់ពីរនាក់មួយទៅហើយ បើចង់លូកលាន់គ្នាចាំបាច់អីគេចទៅឆ្ងាយសំងំបាត់សូន្យបែបនេះ?

«ចុះពេជ្រ? មិញដែលថាពេជ្រមានមនុស្សក្នុងបេះដូងហ្នឹងជាអ្នកណា?!» នាងសួរខ្សឹបៗទៅសង្សារ។

ឌីខ្សឹបវិញភ្លាម៖

«ម៉ាលីដឹង!»

«ម៉េចច្បាស់ម៉េស?!»

«អារម្មណ៍ប្រុសដូចគ្នា!»

«ពិតអត់? ចុះម៉េចបណ្ដោយឱ្យបាត់ម៉ាលីបាន?!»

«គេរកឃើញគ្នាហើយដឹង? គេសំងំស្វីតផងពេលនេះ!»

«កុំប៉ុនតែស្មានទៅរករឿងម្យ៉ាងហ្នឹង! បើមិនបានឃើញគ្រប់គ្នាទេ ខ្ញុំមិនទុកចិត្តទេឌីន! គេងក៏មិនលក់ដែរយប់នេះ!»

«មានពីណាហៅខ្លួនមកគេង!»

នាងក្តិចខាងប្រុសញាប់ដៃ ព្រោះគេនេះចេះតែលកលែរខ្លួនមករកនៃបនិត្យ។

ប្រាវ....

ស្នូរជើងមនុស្សរត់កាត់.....

ទាំងពីរប្រាណបង្អន់ក្តិបន្លែងឆាបឆេះ ហើយត្រង់ខ្លួនផ្ទង់ស្តាប់។

«អ្នកណា?!»

ឌីនស្រែកសួរទាំងភ្នែកធំៗ ដៃរេចាំងពន្លឺពិលចច្រប់សម្លឹងជុំវិញព្រោះស្នូរដង្ហើមមនុស្សនិងសភាពដូចមានអ្នកណាម្នាក់រត់មកដួលគឺនៅជិតនឹហងអ្នកទាំងពីរបង្កើយហើយ។

មិនដល់ប្រាំឬប្រាំមួយម៉ែត្រពីកន្លែងដែលយុវវ័យទាំងពីរកំពុងតែឈរដោយញ័រដៃជើងនោះទេ.....

«ជួយ!ជួយ!ជួយខ្ញុំផង!»

សំឡេងពេជ្រ ?

ភិនដានិយាយញ័រហើយតោងដៃឌីន ធ្វើឲ្យឌីនក្រសោបម្រាមដៃរបស់សង្សារវិញភ្លាមដែរ។ ដៃឌីនម្ខាងទៀតខំកាន់ពិលយ៉ាងណែន រួចរេតម្រង់ទៅរកប្រភពនៃសូរសំឡេង។

ពួកគេពិតជាបានឃើញស្បែកជើងមួយគូលៀនចេញមកពីក្នុងគុម្ពោតព្រៃ។

«ច្បាស់ណាស់គឺជាស្បែកជើងរបស់ពេជ្រ!»

ភិនដានិយាយទៀត។ មុននេះពួកគេបានសង្ស័យថា ពេជ្របានទៅជាមួយម៉ាលីដែលបានបាត់ខ្លួន។ ទោះបីថាពេជ្រនិងម៉ាលីសុទ្ធតែជាយុវវ័យមិនទាន់មានគូស្នេហ៍ ក្នុងចំណោមពួកគេទាំងប្រាំបីនាក់ប៉ុន្តែអ្នកណាក៏ដឹងបានថា អ្នកទាំងពីរកំពុងតែមានចិត្តទោរទន់ឲ្យគ្នាដែរ គ្រាន់តែថាម៉ាលីបានបាត់ខ្លួនទៅមុន ឯពេជ្រក៏ទៅតាមស្វែងរកនាងតាមពីក្រោយ។

«ពេជ្រ? ពេជ្រមែនអត់?»

ភិនដាវ៉ាចាស្ទួរទាំងញាប់ញ័រដៃជើង ចំណែកឌីនវិញនិយាយអីមិនចេញតែម្តង។ ទោះបីជាខ្លួនឯងជាប្រុសហើយឌីនតែងធ្វើឫកខែងរ៉ែងរបៀបថាមិនភ័យខ្លាចអ្វីផ្ដាស ប៉ុន្តែពេលនេះដៃរបស់ឌីនពិតជាត្រជាក់ខ្លាំងណាស់។

«ជួយ! ជួយខ្ញុំផង!»

សំឡេងពេជ្រតបមកវិញស្អកៗ។

«គេមានរឿងហើយ!» ភិនដាប្រាប់សង្សារញ័រៗ។

«តោះទៅមើលពេជ្រ» នាងនិយាយតឿនទៀតរួចមទាញដៃឌីនទៅ ប៉ុន្តែខាងប្រុសនៅរាងស្ទាក់ស្ទើរ។

«យើងទៅរកហៅមនុស្សមកសិនឬក៏យ៉ាងម៉េច?!»

«អត់ទេ!»

បដិសេធហើយភិនដាលែងដៃពីឌីន ធ្វើឲ្យខាងប្រុសរត់តាមពីក្រោយ ខណៈកាន់ពិលចាំងបំភ្លឺឲ្យនាងផង។

ហាក់មិនគិតពីខ្លួនឯង ភិនដាស្រែកផងរត់ចូលផង៖

«ពេជ្រ! ពេជ្រ! មានរឿងអី? ពេជ្រកើតអី? ដួលឬក៏យ៉ាងម៉េច?!»

«ជួយខ្ញុំផង ភិនដា ជួយខ្ញុំផង!»

សភាពឆ្លើយតបរបស់ពេជ្រ បង្ហាញថាគេនៅដឹងខ្លួនហើយចូលទៅដល់ភ្លាមអ្វីដែលពួកគេបានឃើញ គឺមិត្តកំពុងននៀលទៅលើដី ប៉ុន្តែមិនមានរបួសអ្វីធ្ងន់ក្រៅតែពីទន់ជើង ទន់ជង្គង់នោះទេ។ ឯដៃរបស់គេក៏ចង្អុលទៅកាន់អ្វីម៉្យាង គឺផ្លូវឆ្ពោះទៅកាន់ខ្ទមដាក់ឧស។

«ស្អីគេ? មានរឿងអីនៅខ្ទមលក់អុស?» ឌីនសង្ឃើញខ្សឹបសួរកណ្តាលស្បែរាត្រី។

«នីននិងអារ៉ុធ……ពួកវា…..» ពេជ្រនិយាយបានតែខ្លីៗបែបនេះរួចរលត់កណ្ដាលសភាពតក្កមា។ ធម្មតាអ្នកណាក៏ដឹងដែរថា ពេជ្រគឺជាមនុស្សប្រុសសុភាពរាបសាទន់ភ្លន់ គេមិនមានសង្សារមកជាជាមួយ ប៉ុន្តែគេគិតដល់នារីៗទាំងអស់នៅលើឡានដែលមកជាមួយគ្នា មិនថាអ្នកណាជាអ្នកណាទេ។ ពេលនេះគេទៅស្វែងរកម៉ាលីដែលបាត់ពីតង់ ប៉ុន្តែគេប្រហែលជាប្រទះឃើញអ្វីម៉្យាងគួរឲ្យភ័យខ្លាចហើយមើលទៅបានជាត្រូវតក់ស្លុតមករបៀបនេះ។

«ម៉ោះ! អត់អីទេណា៎ អត់អីទេ! ពេជ្រ! ខ្ញុំនៅហ្នឹង ឌីនក៏នៅហ្នឹង!»

ភិនដានិយាយទាំងបោះដៃទៅឱ្យពេជ្រ ចំណែកឌីនគិតតែពីចង់តម្រង់ទៅខ្ទមលក់ឧសដែលពួកគេកំពុងមានបំណងដើរតម្រង់ទៅរកមិត្តឈ្មោះហ៊ាងនិងGen ប៉ុន្តែចៃដន្យឃើញពេជ្រនៅទីនេះ។

តាមស្មានពេជ្រប្រហែលជាទើបតែមកពីកន្លែងនោះ។

«មនុស្សនៅណេះមិនគិត ទៅគិតអីខ្ទមឧសនោះទៅវិញ?!» ត្រូវភិនដាស្តីបន្ទោសឲ្យឌីនហាក់លែងអន្ទះសា បែរមកវិញជួយលូកដៃទទួលឲ្យពេជ្រតោង។

ភិនដាស្ទុះទៅគ្រាហ៍ពេជ្រឡើងជាមួយគ្នាដែរ។ អ្នកទាំងពីរលើកពេជ្រដើរចេញពីគុម្ពោតមកផ្លូវខាងក្រៅខណៈ ពេជ្រចាប់ផ្ដើមយំនិងនិយាយទាំងរអាក់រអួល៖

«អារ៉ុធស្លាប់ហើយ!»

ដៃឌីនរបូតពីប្រាណគេ ខណៈពេជ្រចាប់ផ្ដើមយំគគ្រូកធ្វើឲ្យភីនដាញ័រដៃស្ទើរតែរបូតពីការគ្រាហ៍នេះដែរ។

«នីន!»

នាងរអ៊ូហៅឈ្មោះមិត្តតិចៗព្រោះនីនទៅជាមួយរ៉ុធ បើពេលនេះពេជ្រអះអាងថារ៉ុធស្លាប់ចុះនីន?

ចុងក្រោយពេជ្របាននាំទាំងពីរកាយដែលភ័យរន្ធត់ ដើរមកឃើញសាកសពនីននិងរ៉ុធនៅក្នុងរបងខ្ទមលក់ឧស។

«មិនបានទេយើង! ទៅរកប៉ូលិស! យើងត្រូវតែទៅរកអាជ្ញាធរ! តោះយើង! ទៅប្ដឹងៗៗ!»

ឌីននិយាយហើយប្រុសៗទាំងពីរងាកមកភិនដាដែលកំពុងតែឈរញ័រដៃចំប្រប់សម្លឹងទៅរកសាកសពរបស់នីន។ នីនទើរនៅលើបង្កាន់ដៃឈើ ឈាមទាំងថ្លុក សង្សាររបស់នាងគឺរ៉ុធក៏ដេកផ្ងារជើងចង្រ្កាងនៅផ្ទាល់ដីតែម្ដង។

ដោយសារទីនេះមានអំពូលភ្លើងព្យួរតែកតោកក្រហមងងាល ពួកគេអាចឃើញសាកសពទាំងពីរច្បាស់សូម្បីតែមិនទាន់ចូលទៅដល់ជិត។ ភ្នែកភិនដាខំរេរកមើលម្ចាស់ខ្ទម ជាបុរសវ័យកណ្ដាលម្នាក់ដែលយុវវ័យទាំង៨ពិតជាបានជួបមុនពេលចូលមកបោះជំរុំកាលពីល្ងាច។

«តោះតោះៗភិនដា! ភិនដា!»

ពេជ្រហៅនាងយ៉ាងតក់ស្លុតទាំងស្ទុះមកទាញដៃភិនដាចេញ ប៉ុន្តែនាងហាក់បីដូចជាជាប់ស្មិតឈានមិនរួច ។

«ភិនដា!»

គេស្រែកខ្លាំងៗដាក់ត្រចៀកនាង ទើបនាងដឹងខ្លួនមកវិញខណៈកំពុងត្រូវប្រុសទាំងពីរទាញចេញមកឆ្ងាយឡើងៗពីអ្នកស្លាប់។

ទាំងវង្វេងចិត្ត ភិនដាសម្លឹងពេជ្រ រួចហើយសម្លឹងឌីនទាំងគ្រវីក្បាលបដិសេធ៖

«អត់ទេ! នីននិងវុធមិនស្លាប់ទេ!»

ឌីនគ្រវីក្បាលទៅនឹងកែវភ្នែកតក់ស្លុតស្មើរឆ្កួតស្មារតីរបស់សង្សារ។ គេដឹងថា នេះជាព្រឹត្តិការណ៍តក់ស្លុតណាស់ នាងទទួលយកមិនបាននិងមិនទាន់ប្រមូលអារម្មណ៍បានមកវិញមួយរយភាគរយទេ។

«តោះ! តោះ! ដាយើងទៅវិញសិន!»

«នីនៗៗ» នាងខំស្រែកហៅមិត្តទាំងប្រឹងរលាស់ដៃចេញដូចជាចង់ចូលទៅរកសាកសព ប៉ុន្តែពេជ្រនិងឌីនប្រមលូកម្លាំងពលំទាញនាងថយក្រោយមកវិញ ធ្វើឲ្យភិនដាស្រែកយំគ្រវីក្បាលតតាត់៖

«អត់ទេ! នីនមិនស្លាប់ទេ! នីនមិនចង់មកទេប៉ុន្តែខ្ញុំបានបបួលគេមក! គេថា គេមិនចង់មកចំណុចក្រហមទេ ប៉ុន្តែខ្ញុំថាបើគេមិនមក ខ្ញុំក៏មិនមកដែរ! ឥឡូវនេះហេតុអីបានជាចំណុចក្រហមធ្វើឱ្យមិត្តខ្ញុំស្លាប់? នីនដឹងខ្លួនឡើង ឌីន ពេជ្រលែងដៃខ្ញុំ ខ្ញុំត្រូវការហៅវា វាគ្រាន់តែសន្លប់ វាគ្រាន់តែរបួសទេ វាមិនស្លាប់ទេ!»

ឌីនឱបសង្សារដាក់មាត់ទៅលើថ្ងាសនាងឱ្យនាងឈប់រើ។ ពេជ្រវិញខំខ្សឹបប្រាប់៖

«ឈាមហូរច្រើនណាស់ភិនដា! ឯងមើលទៅ! ហើយករបស់នីនក៏ដាច់បាត់ទៅហើយ ធ្វើម៉េចរស់បាន?»

ឮពេជ្រពន្យល់ភិនដាឈប់មាត់ទាំងភ្នែកស្លឹៗ សម្លឹងមុខឌីនដែលកំពុងតែឱបខ្លួននិងងាកមកមើលពេជ្របញ្ជាក់។ សន្សឹមៗនាងងាកក្រោយមើលសាកសពនីនទៀត។ លក្ខខណ្ឌរបួសរបស់នីនធ្វើឱ្យភិនដាលេបទឹកមាត់បង្កើនភាពក្លាហានកុំឲ្យភ័យខ្លាចពេកក្នុងការមើលសាកសពឱ្យជាក់ តែបើទោះបីជាព្យាយាមយ៉ាងណាក៏សាជាថ្មីនាងមើលឃើញគ្រប់យ៉ាងដូចពេជ្រទើបនឹងប្រាប់។

នីនពិតជាដាច់ត្រង់បំពង់ដង្ហើមដូចមានគេចាប់អារសម្លាប់ ហើយក៏ដួលរលេទៅទ្រាបលើបង្កាន់ដៃឈើពិតប្រាកដមែន។

នៅពីក្រោមនោះថ្លុកឈាមយ៉ាងធំកកមួយកំភ្លូសបង្ហាញថានាងគ្មានសល់អ្វីក្នុងរាងកាយទៀតនោះទេមានរឿងអីត្រូវនៅរស់?

ក្រឡេកភ្លាមមួយរំពេចមករកសង្សាររបស់នាងគឺវុធ គេនេះក៏បានដាច់ជើងមួយចំហៀង ដូចជាត្រូវនឹងកាំបិតផ្ដាក់ហើយជើងមួយចំហៀងនោះក៏មិននៅឆ្ងាយពីសាកសពរបស់គេឡើយ។

ចំណែកករបស់គេក៏មានសភាពដូចជានីនដែរ។

«ពួកគេស្លាប់ហើយហេតុអី?!»

នាងយំខ្សឹកខ្សួលៗហើយងាកមករកពេជ្រ។

«ពេជ្រ? អ្នកណាធ្វើអីពួកគេ?!»

«តោះឆាប់ចេញចេញពីកន្លែងនេះ!»

ពេជ្រឆ្លើយហាក់ដូចជាមានស្មារតីភ្លឺស្វាងជាងមុននិងប្រញាប់ប្រតេងប្រតោងទាញរាងកាយភិនដាយកទៅជាមួយនិងឌីន។

ទោះបីយ៉ាងណានាងហាក់ទន់ជង្គង់ពេក ឈានទៅមិនបានគេយោងពីរនាក់ហើយយោងមិនចង់រួចសោះ។ នាងនៅតែសួរដដែលៗ៖

«ម្ចាស់ខ្ទមលក់ឧសនោះ គេជាអ្នកធ្វើមែនទេ? គេធ្វើមកលើពួកយើងធ្វើអីទៅ?!»

«យើងមិនដឹងទេ! មុនពេលមិនដឹងរឿង យើងមិនអាចនិយាយអ្វីបានទាំងអស់!» ឌីនតបតិចៗ។

«ខ្ញុំគិតថាយើងគួរតែចូលទៅក្នុងខ្ទមនោះរកទូរសព្ទ ឬរកអ្វីមួយដែលអាចទាក់ទងទៅប៉ូលិសបាន!» ពេជ្រនិយាយឡើយដោយឈប់ជើង។

ពួកគេឈប់ជើងដំណាលគ្នាទាំងនៅគ្រាភិនដាក្នុងដៃនៅឡើយ។ ប៉ុន្តែពេជ្រដៀងភ្នែកសម្លឹងឌីនចំណែកភិនដាវិញ នាងងាកទៅសំលឹងខ្ទមភ្លឺះៗ ធ្វើឲ្យពេជ្រសម្លឹងទៅទីនោះវិញដូចគ្នា។

ឌីនចាប់ផ្ដើមប្រាប់៖

«ទូរសព្ទរបស់ពួកយើងសុទ្ធតែគ្មានសេវា! នរណាម្នាក់ប្រាកដជាបានដាក់អ្វីម៉្យាងនៅតំបន់នេះរាំង មិនឱ្យសេវាទូរសព្ទមកប៉ះឧបករណ៍របស់យើងបាន! ដូច្នេះនៅក្នុងខ្ទមនេះក៏កុំសង្ឃឹមថាមានអ្វី ទាក់ទងទៅក្រៅបានឲ្យសោះ!»

«Genនិងហ៊ាងដំបូងគេថាមកខ្ទមឧសនេះដែរ គេចង់មករកឧសយកទៅដុត!»

ភិនដារំឭកនិយាយទាំងដៃនាងតោងប្រុសៗទាំងពីរ។ ម្រាមស្រីពិតជាត្រជាក់ល្ហកណាស់។ នាង ចង់រកមិត្តពីរនាក់ទៀតសិនមុនពេលចាកចេញ....

«Gen? ហ៊ាង?»

នាងហៅឈ្មោះគូស្នេហ៍មួយគូនេះច្រើនដងណាស់....នាងស្រែកខ្លាំងៗ....ប៉ុន្តែឮតែសំឡេង របស់ខ្លួនឯងផ្ទាល់មកវិញនិងការអមមកជាមួយនូវស្នូរស្លឹកឈើប្រោកៗដោយសារត្រូវប៉ះដោយ កម្លាំងវាយោ នាយប់អធ្រាត្រសែនត្រជាក់រហោឋាន។

«ចុះអ្នកលក់ឧសនោះបាត់ទៅណា? ខ្ញុំគិតថាគេនៅក្នុងខ្ទម ទោះបីមិនមានទូរសព្ទក៏យើងអាចរក ឃើញអ្វីម៉្យាងដើម្បីការពារខ្លួនដែរ!»

ឌីនបន្ថែមបែបនេះធ្វើឱ្យពេជ្រងក់ក្បាលស្របជាមួយ ។ សម្ដីឌីនធ្វើឲ្យភិនដាយល់បានថាប្រុសៗ ទាំងពីរប្រាណកំពុងគិតទៅដល់ពូថៅឬក៏កាំបិតយកមកតាមខ្លួន។

ចិត្តនាងភ័យស្លុតខណៈពួកគេទម្លាក់ដៃពីនាង។

«ឈរចាំខ្ញុំនៅហ្នឹងហើយ!»

ថាហើយពួកគេរត់ចូលទៅក្នុងខ្ទម។

ភិនដាយកដៃក្រពាត់រាងកាយខ្លួនឯងកុំឲ្យរងាក្រោមការវាយមកសន្ធាប់ដោយខ្យល់លាយ សន្សើម។ ទោះបីនាងកំពុងភ័យខ្លាំងក៏ច្រមុះនាងចាប់ផ្ដើមទទួលយកលែងបាននូវក្លិនឈាមឆ្អាប។

សម្រែកខ្សាវៗលាន់មកពីខាងណាមួយ....

«ជួយ! ជួយខ្ញុំផង! ជួយខ្ញុំផង!»

មិនមែនសំឡេងរបស់មិត្តភក្តិនាងទេ នាងដឹង។ ភិនដាថយក្រោយក្រាកមួយជំហានខណៈយល់ ថាការដង្ហោយ ស្អកៗ កំពុងតែបានកើតមានលើងចេញពីជ្រុងខាងត្បូងនៃបរិវេណផ្ទះខ្ទមនេះ។

ជាសំឡេងរបស់ អ្នកភូមិដែលមានលក្ខណៈចម្លែកមិនដូចអ្នកនៅទីក្រុង តែរដឹនហើយ នាងចាំបានច្បាស់។

«ពូលក់ឧស?!»

បុរសវ័យកណ្ដាលជាអ្នកលក់ឧសដែលពួកនាងបានមកសួរផ្លូវការពីទើបនឹងមកដល់។ ភិនដាដើរថយក្រោយទៀត ក្រាក់ៗខណៈឃើញគាត់អើតកមកពីដីងងឹតមយយក្រោមដើមអម្ពិល។ នាងថយទាល់តែខ្លួនឯងទាក់ជំពប់ជើងរអិលនិងមែកឈើដួលអុកគូទទៅនឹងដីក្រោកលែងរួចនៅនឹងកន្លែង។

ប្រុសៗទាំងពីររត់ចេញពីក្នុងខ្ទមមកដល់ ពេលឮសម្រែកស្រែកវាស់របស់នាង។

ពេលនេះនាងមិននិយាយអ្វីរួចទៀតឡើយ គិតពីយកដៃទៅចង្អុលទៅចំហៀងខ្ទមនៅត្រង់ច្រកម្លប់សាខា។ អ្នករបួសកំពុងវាចេញមកហើយ....ឲ្យរាងកាយរបស់គាត់ដូចជាយ៉ាប់យឺនខ្លាំងធ្វើឱ្យយុវវ័យទាំងបីចំហមាត់ផ្លុងព្រោះស្លុត។

ពេលដែលគាត់វាមកទីមានពន្លឺ ពួកគេឃើញថាជើងរបស់គាត់ក៏បាត់មួយចំហៀងដូចសាកសពរបស់វុធដែរ។

ពេជ្រនិងឌីនស្ទុះមកទាញភិនដាក្រោកឡើង ហើយអូសនាំនាងរត់ចេញទៅក្រៅ ចាកចេញផុតពីរបងខ្ទមនេះ។ ទោះយ៉ាងពួកគេមកឈប់នៅមាត់ទ្វាររបងសម្លឹងមកសភាពអ្នកលក់ឧសនៅខាងក្នុងដែលលែងវាររួចនិងត្រដរខ្យល់នៅក្នុងថ្លុកឈាម។

«អ្នកណា? អ្នកណាសម្លាប់គាត់?!»

ឌីនរអ៊ូញ៉រៗ ខណៈពួកគេឃើញបុរសអ្នកលក់ឧសប្រកាច់ទាំងលើកដៃចង្អុលមុខប្រុសស្រីទាំងបីផង។

អាការៈនេះធ្វើឲ្យភិនដានិយាយឡើងទាំងញ័រៗ៖

«ជួយ! ជួយគាត់ផង! គាត់នៅរស់ទេ!»

ពេជ្រប្រកែកភ្លាមទាំងញាប់ញ័រដូចគ្នា៖

«អត់ទេ! គាត់ជិតស្លាប់ហើយ! យើងមិនអាចជួយគាត់បានទេដា! ឈាមហូរច្រើនណាស់! ជើងគាត់ក៏ដាច់ដែរ! យើងគ្រាប់គាត់មិនរួចទេ!»

«ហើយ.....តើអ្នកណាធ្វើ?»

ដៃរបស់ពេជ្រម្នាងកាន់ញញួរមួយតូច ដែលមិនសក្តិសមអាចការពារខ្លួនអ្វីបានប៉ុន្តែវាប្រសើរជាងគ្មាននោះដែរ។ ចំណែកឯដៃរបស់ឌីននៅតែ កាន់ពិលយ៉ាងជាប់ម៉ឹងព្រោះនេះគឺជាឧបករណ៍ដ៏សំខាន់សម្រាប់ពួកគេក្នុងការចាកចេញពីព្រៃមួយនេះ។

«តោះយើងទៅ!»

ឌីនចាប់ផ្តើមទាញប្រុសស្រីទាំងពីរឲ្យរត់ទៅតាមខ្លួន។

ពួកគេរត់ចេញតាមទិសផ្សេង មិនមែនជាទីដែលពួកគេបានរត់មកអម្បាញ់មិញនោះទៀតឡើយ។ សេចក្តីសង្ឃឹមថា នឹងរកឃើញអ្នកភូមិឬមិត្តបីនាក់ទៀតហាក់កាន់តែក្លាយជារឿងគួរឱ្យពិភាល់ទៅៗ។

«គ្រប់យ៉ាងដូចជាមាននរណាម្នាក់បានរៀបចំវាឡើង? ពួកគេអាចដឹងពីដំណើររបស់យើងមុន? ឬមួយក៏មនុស្សព្រៃ ឃាតកៈមកដល់ចំណុចក្រហមនេះដោយចៃដន្យ?»

ឌីនសួរនេះយោងតាមភាពរវើរវាយនៃអារម្មណ៍ដែលបាចហាចឥតព្រំដែនរបស់ខ្លួន។ ពេជ្រក៏និយាយតិចៗ៖

«គ្មានអ្វីដែលជារឿងល្អឡើយសម្រាប់យប់នេះ! Genនិងហៀង មិនដឹងថានៅឯណា ខណៈដែលម៉ាលីអ្នកបាត់ខ្លួនមុនគេក៏មិនឃើញសូម្បីតែស្រមោល ឬទាំងបីក៏បានស្លាប់បាត់ទៅហើយ?»

ការនេះធ្វើឲ្យភិនដាព្រឺហើយក៏ដើរទាំងយំគគ្រូកតែម្តង។

ទោះយ៉ាងណាពេជ្រប្រញាប់កែសម្តីធ្វើជានិយាយជាមួយឌីនវិញ៖

«យើងគ្មានពេលគិតទេ! យើងត្រូវការរកមិត្តភក្តិរបស់យើង ឬក៏យើងរកអាជ្ញាធរឲ្យឃើញសិន!»

«អាជ្ញាធរស្អីទៅ? ពួកគេមិនដឹងនៅឯណាផង! បើសិនជារកឃើញនោះពូលក់អឧសប្រហែលជារកឃើញមុនយើងទៅទៀត!»

ភិនដាយំខ្សឹបខ្សួលឃាត់៖

«កុំឈ្លោះគ្នាអី! ខ្ញុំចង់ឃើញ Gen និងហ៊ាង ! Gen? ហ៊ាង? ម៉ាលី?»

ពួកគេស្រែកហៅបន្តគ្នាហើយ រត់កាន់តែឆ្ងាយទៅៗចេញពីរខ្ទមលក់ឧសរហូតដល់ដីផ្លូវដែកចាស់មួយ។

អាកាសធាតុកាន់តែរងាទ្វេឡើងក្រោមស្រទាប់សន្សើមធ្លាក់រពុយ។ អំពូលសូឡានៅតំបន់នេះមិនមានច្រើនទេ តែមានខ្លះដែរ ជះប្លុងៗមកពីឆ្ងាយៗ។

«ប្រាប់ថាឱ្យទៅដេកResort គេធម្មតាទៅគេមានអ្នកយាមកាមត្រឹមត្រូវ អត់ទេ នាំគ្នាចូលព្រៃ! នេះហើយតំបន់ក្រហមរបស់ពួកឯង!»

ពេជ្របន្ទោសបែបនេះប៉ុន្តែឌីនក៏លែងនិយាយអ្វីចេញដែរ ព្រោះធម្មតាឌីនជាអ្នកចូលចិត្តបង្ហាញឫទ្ធដល់ស្រីៗ ចង់តែនាំស្រីស្អាតរបស់គេផ្សងព្រេងនៅតាមតំបន់អន់សុវត្ថិភាពបញ្ជាក់ថាគេមិនចេះខ្លាចអ្វី។

មិនយូរប៉ុន្មាន នៅឆ្ពេលគ្លាលើផ្លូវរថភ្លើងចាស់ ពួកគេក៏ប្រទះឃើញស្នាមដានឈាម។

«អូយ! (ពេជ្រស្រែកឡើង) ខ្ញុំគិតថារឿងគឺកាន់តែលំបាកជ្រៅទៅៗហើយអ៊ើយ!»

«មានអីត្រូវគិតទៀត? មនុស្សស្លាប់នៅនឹងមុខដល់ទៅបីនាក់ទៅហើយ គ្មានអីដែលថាត្រូវគិតទៀតនោះទេ!»

ឌីនចរចាតបទាំងចោលភ្នែកមុតថ្លាសម្លឹងជុំវិញខ្លួនមួយៗគ្រប់ទិសទីហាក់ប្រុងប្រយ័ត្នខ្ពស់។

«ស្អីនោះ?! ជួយមើលគ្នា!»

នោះជារបស់អ្វីម៉្យាង.....ពួកគេទើបតែមើលវាឃើញតាមពន្លឺពិលដែលបញ្ចាំងចំទៅ។

«នាឡិការបស់ហ៊ាង?»

ភិនដានាងស្គាល់នាឡិការបស់ហ៊ាងច្បាស់។ ហ៊ាងគឺជាមិត្តប្រុសរបស់Gen ដែលជាមិត្តស្រីស្និទ្ធស្នាលរបស់នាងម្នាក់ដែរ។ Genហើយនិងនីនតែងតែសាសង រៀបរាប់គ្រប់រឿងរ៉ាវនៃជីវិតស្នេហារបស់ពួកនាងមកប្រាប់ភិនដា។ នៅចាំបានដែរថានាឡិការបស់ហ៊ាងដែលកំពុងតែដេកក្បែរតំណក់ឈាមវែងអន្លាយលើផ្លូវរថភ្លើងចាស់នេះ ជានាឡិកាដៃដែលGen ខំសន្សំលុយជាយូរមកហើយដើម្បីទិញជូនហ៊ាងក្នុងថ្ងៃខួបកំណើត២១ឆ្នាំ។

ភស្តុតាងកម្រមួយនៅលើផ្លូវរថភ្លើងចាស់និងស្ថានការណ៍ពេលនេះមិនបានបង្ហាញអ្វីវិជ្ជមានថាមនុស្សទាំងពីរនាក់ដែលពួកគេកំពុងស្វែងរក នៅរស់រានមានជីវិតនោះទេ។

បើផ្អែកទៅតាមអ្វីដែលពួកគេបានឃើញនៅខ្ទមលក់ឧសនិងនាឡិកាបែកមួយនេះ បេះដូងភិនដាជិតគាំងហើយ។ ស្រីតោងដៃឌីនហើយយំ។ ខ្លួននាងធូន់ទៅៗធ្វើឲ្យគ្រប់គ្នាដើរទៅមុខទៀតមិនចង់រួចទេ។

សូម្បីតែប្រុសទាំងពីរនាក់ដែលខំធ្វើឫកមាំ ផ្ទង់សម្លឹងជុំវិញខ្លួននោះក៏កំពុងតែញញើតញញើមមិនដឹងថាត្រូវបន្តដំណើរទៅមុខឬបកក្រោយនោះដែរ។

ពេជ្រឱនរើសនាឡិកាមកពិនិត្យ។

ឌីននិយាយដោយគ្រហឹមៈ

«ឃាតកៈជាអ្នកណា?!»

«យើងមិនដឹងទេ! វាធ្វើដើម្បីអ្វី?!»

ពេជ្រឆ្លើយដោយមួហ្មង ហើយហុចនាឡិកាមកឱ្យភិនដា។ ភិនដាក៏ទទួលយកទាំងទឹកភ្នែកសឹងខ្សោះកាយទៅហើយ។

ដៃនាងញ័រព្រោះនឹកដល់សម្ដីGen «យើងសន្សំលុយរហូតមកព្រោះហ៊ាងគេចង់បាននាឡិកានេះ» ។ នាងយំដាក់ពេជ្រ ភ្នែកនឹងភ្នែកប៉ះគ្នាជ្រាលជ្រៅដល់បេះដូង នាងចង់ប្រាប់អ្នកដែលកំពុងហុចនាឡិកាមកនេះថានាងខ្លាចផ្សាណាស់ តែមាត់ភិនដានិយាយមិនរួចបានត្រឹមស្រែកទង្គិចក្រោមក្រសែភ្នែកពេជ្រដែលសម្លឹងមកយ៉ាងខ្ជាប់ខ្ជួន។ គេសម្លឹងភិនដា ហាក់ចង់ឱ្យនាងដឹងដែរថា គេយល់ចិត្តនិងអាណិតនាងណាស់ ហើយគេមិនទៅណាទេ គេនឹងការពារនាងឱ្យមានសុវត្ថិភាព។

ឌីនមិនដឹងថាមានអ្នកកំពុងលបលួចមើលសង្សារខ្លួនក្នុងន័យអាណិតជ្រាលជ្រៅបែបនេះទេ គេគិតពីផ្ទុះកំហឹងទាត់បំបើុងជុំថ្ម ស្រែកឡូងៗៈ

«ឥឡូវនេះវាកំពុងឃើញយើងឬអត់?!»

ពេជ្រងាកទាញអារម្មណ៍ចេញពីការស្ដែងអាណិតភិនដា។ គេមកសម្លឹងសង្សារភិនដាដែលកំពុងបញ្ចាំងពិលពិនិត្យផ្លូវចុះឡើងៗដូចឆ្កួតវង្វេង។ គេនិយាយតបនឹងឌីនៈ

«យើងក៏មិនដឹងដែរ! តែ.....!»

«តែស្អី?!»

«ខ្ញុំគិតថា ការឈរនៅកណ្ដាលវាលមិនមែនជាមធ្យោបាយល្អទេ!»

ភិនដាសួរទាំងយំរអាក់រអួលៈ

«តើយើងធ្វើយ៉ាងម៉េចទៅពេជ្រ!»

ពេជ្រងាកមកសម្លឹងនាងដោយស្រទន់ គេតបខ្សឹបៗៈ

«យើងមិនគួរនៅកណ្ដាលវាលទេ! យើងបីនាក់រកកន្លែងងងឹតមួយលាក់ខ្លួន ជាជាងមកឈរឱ្យវាមើលឃើញយើងដោយស្រួលបែបនេះ!»

«ត្រូវ! (ភិនដាបន្ទរ) ខ្ញុំចង់ឲ្យពួកយើងលាក់ខ្លួនសិន ខ្ញុំគិតថាយើងគួរតែរកកន្លែងលាក់ខ្លួនទៅឌីន!»

ឌីនសៅហ្មងនិយាយទ្រគោះសូម្បីតែជាមួយសង្សារៈ

«លាក់ខ្លួននៅឯណាទៅ? ចូលព្រៃ? សុទ្ធតែព្រៃងងឹតហើយយើងមិនស្គាល់ផ្លូវដូចម្ចាស់ស្រុកគេទេ!»

ភ្លាមនោះពេជ្រមានយោបល់ៈ

«អុះ! ខ្ញុំនឹកឃើញហើយ នៅក្បាលផ្លូវដែកចាស់នេះដូចជាមានតូបចាស់មួយ បើយើងទាំងបីទៅពួននៅហ្នឹង យ៉ាងហោចណាស់ក៏យើងមានកន្លែងមួយសម្រាប់មើលជុំវិញខ្លួនយើងប្រុងប្រៀបចាំទទួលវាដែរ! ចាំដល់មេឃភ្លឺសិនចាំគិតទៀត!»

នាងធ្វើដំណើរត្រុកៗទៅតាមពួកគេទាំងចិត្តបែរបន់យ៉ាងណាឲ្យមេឃភ្លឺឆាប់ៗ។ ប៉ុន្តែនាឡិការបស់ហ៊ាងដែលឌីនលើកមកបញ្ចាំងមើលនោះ ប្រាប់ហើយថា ម៉ោងទើបតែមួយអធ្រាត្រតែប៉ុននោះ។

ពេលវេលានៅវែងឆ្ងាយទៀតណាស់។

ងាកទៅម្ខាង ភិនដាឃើញពេជ្រដៃកាន់ញញួរយ៉ាងណែនប៉ុន្តែម្រាមរបស់គេទាំងមូលជ្រីវជ្រួញញាប់ញ័រ។ នាងដឹងថាគ្មានអ្នកណាដែលមិនទាយដឹងពីវាសនារបស់ម៉ាលីទេ។

ដើរតាមប្រុសៗទាំងពីររហូតដល់កន្លែងតូបតូចមួយដែលពេជ្រនៅចាំបាន គឺពិតជារកឃើញមែន។ នោះជាទូដែកសម្រាប់អ្នកយាមផ្លូវដែកកាលពីយូរមកហើយ។

ដោយសារវាត្រូវបានគេបោះបង់ចោល គ្មានមនុស្សសម្អាត នៅខាងក្នុងតូបស៊ុបទ្រុបទៅដោយស្មៅ។

ប៉ុន្តែពួកគេបានសម្រេចចិត្តចូលទៅអង្គុយក្នុងនោះ ហើយពេជ្រកាប់កូនដើមឈើចោលខ្លះ។

«យើងច្បាស់ជាត្រូវមូសខាំមួយយប់ទល់ភ្លឺហើយ!» ឌីនរអ៊ូ។

«យ៉ាងហោចណាស់ក៏គ្រាន់បើជាងត្រូវពួកឃាតកៈអារផ្ដាច់សរសៃកឲ្យយើងដកដង្ហើមលែងរួចនោះដែរ!»

វាជាអ្វីដែលយុវជនទាំងពីរឆ្លើយឆ្លងគ្នា ចំណែកនាងវិញគិតពីខ្ទប់ត្រចៀកអង្គុយចោងហោងយំខ្សឹកខ្សួល ទីបំផុតដោយសារហត់នឿយពេកឌីនក៏អង្គុយផ្ទាល់ទៅលើកម្រាលស្មៅក្នុងតូបនោះ ហើយហៅនាងឲ្យមកអង្គុយលើខ្លួនគេ។

ភិនដាដោយមិនដាច់ចិត្តបង្អើនទម្ងន់ខ្លួនទៅលើខ្លួនសង្សារក៏ប្រះអង្គុយក្បែរឌីន ហើយផ្អេកស្មាគេ។

«ខ្ញុំអស់កម្លាំងខ្លាំងណាស់!»

ពេជ្រងាកមកប្រាប់៖

«គេងទៅខ្ញុំយាមផ្លូវឱ្យ!»

«គេងមិនលក់ទេ ខ្ញុំត្រូវការទៅផ្ទះ!»

នាងនិយាយដោយអណ្ដឺតអណ្ដក។

«ទូរសព្ទយើងនៅតែគ្មានសេវា ខ្ញុំមិនដឹងធ្វើម៉េចនោះទេ!» នាងថាហើយទុកទូរសព្ទវិញទាំងមិនអស់ចិត្ត។ ស្រាប់តែឌីននិយាយបន្តឡើង៖

«ខ្ញុំបានផ្ញើសារចេញទៅច្រើនហើយ!»

ឮបែបនេះពេជ្រដែលកំពុងឈរបែរខ្នងក៏ងាកមកសម្លឹង។ ឌីននិយាយពន្យល់៖

«មិនមែនរបស់ខ្ញុំមានសេវាទេតែ គិតថាផ្ញើសារទុកឲ្យហើយ ទៅដល់កន្លែងដែលមានសេវា វានឹងលោតសារនោះទៅគេភ្លាម! ហើយពួកគេនឹងមកជួយយើង!»

«ចុះឥឡូវនេះ បើសិនជាមានឮអ្នកណាដើរកាត់យើងគួរតែស្រែកហៅពួកគេដែរឬទេ?!» នាងខ្សឹបសួរឌីន។

«អត់ទេ!» ពេជ្រងាកមកឆ្លើយបានមុន គឺនិយាយដោយប្រុងប្រយ័ត្នទាំងកាយវិការភ្នែកសម្លឹងឆ្វេងស្ដាំផង។

«ទីនេះក្រៅពីពួកយើង តើមានអ្នកណាទៀតទៅ? អ្នកដែលដើរមកមិនប្រាកដថាមកជួយយើងនោះទេ គេ អាចមករកយើងដើម្បីធ្វើបាបយើង ដូចករណី នីន Gen ហ៊ាង ឬវុធដែរ!»

«អ៊ីចឹងធ្វើម៉េចទៅ?!»

នាងសួរទាំងមុខស្លេកស្លាំង ប៉ុន្តែប្រុសៗទាំងពីរទំនងជាមិនឃើញភាពស្លេកស្លាំងរបស់នាងទេ អាចចំណាំតាមរយៈសំឡេងញាប់ញ័របស់នាងតែប៉ុននោះ។

សភាពពេលនេះ មេឃកាន់តែងងឹតខ្លាំងឡើង។ គ្មានទេព្រះចន្ទឬសូម្បីផ្កាយ។ សង្ឃឹមថា គ្មានភ្លៀងចុះព្រោះជាខែកត្តិក ប៉ុន្តែមានពន្លឺព្រាលៗ ឆ្ងាយៗពីភ្លើងសូឡាដែលចាំងលើផ្លូវរថភ្លើងចាស់នៅចម្ងាយប្រមាណជាសាមសិបម៉ែត្រពីគ្នាស្លុងៗ។

«ខ្ញុំគិតថា យើងចែកវេនគ្នាគេងទៅ! បើសិនជាអាចគេងបានសម្ងំៗទៅ! ខ្ញុំជាអ្នកមើលផ្លូវមុន! ពេលខ្ញុំហត់ ខ្ញុំហៅពួកឯងឡើង!»

ឌីនងក់ក្បាលមិនមាត់ ប៉ុន្តែដៃរាវឱបប្រាណសង្សារមកផ្ទប់ទ្រូង ធ្វើឱ្យពេជ្រឃើញហើយងាកមុខចេញវិញ។

ដូចមិនចង់ឱ្យស្រីប្រុសទាំងពីរមានសេចក្តីសុខក្នុងការឱបក្រសោបគ្នាស្ងាត់ៗ ពេជ្រចាប់ផ្តើមសួរទាំងឈរបែរខ្នង៖

«ខ្ញុំសុំសួរបន្តិចដា! មុននេះហេតុអីបានជាភិនដាថាមិនចង់មកចំណុចក្រហមនេះលេងជាមួយក្រុមយើង?»

ដូចខ្លាចថា មានឃាតកៈនៅពួនជិតៗនេះហើយឮ ភិនដាឆ្លើយតបវិញស្រាលៗ៖

«ចំណុចក្រហមនេះ ពីមុនគឺជាResortដ៏ល្បីឈ្មោះមួយណាពេជ្រ ប៉ុន្តែថៅកែដូចជាក្ស័យធនហើយនិងបានបោះបង់ចោលយូរណាស់ហើយ!»

«មានរឿងអីនៅកន្លែងនេះពីមុន? ឮសួរថាមានអ្នកបាត់ខ្លួនហ្មែន?!»

«ត្រូវហើយ! រឿងយូរហើយគឺគ្រូរបស់យើង គាត់ឈ្មោះ ធីម!»

ពេជ្រងាកក្រោយសម្លឹងមកអ្នកទាំងពីរ តែគេមិនមាត់អ្វីបង្អាក់នាងទេ គេចង់ស្តាប់ច្រើនជាង។

ភិនដាឃើញគ្រប់គ្នាដូចង់ដឹងរឿងចាស់មួយនោះ នាងក៏តំណាលបន្តមួយៗ៖

«គ្រូធីមគឺជាគ្រូល្អណាស់ប៉ុន្តែគាត់អកុសល! ពេលមានបេសកកម្មសាលាត្រូវនាំសិស្សមកលេងចំណុចក្រហមនេះ នៅយប់ចុងក្រោយគេគេងអស់ ខ្លួនគាត់ត្រូវបានបាត់ខ្លួន! មានគេនិយាយថា គាត់ឈឺឆ្អាល ស្វែងរកសិស្សស្រីនិងប្រុសដែលពួនលបលាក់អីទៅបង្កើតស្នេហាអនាចារហើយគាត់ខ្លាចពួកគេមានបញ្ហា មានគ្រោះថ្នាក់នៅក្នុងព្រៃ ប៉ុន្តែនៅពេលដែលគាត់មិនចេះហែលទឹក គាត់ក៏រអិលជើងធ្លាក់បឹងមួយ ហើយគ្មាននរណារកគាត់ឃើញទេមកទល់ឥឡូវ!»

«បានហើយឈប់និយាយទៅ!»

ឌីនឃាត់តែពេជ្រតវ៉ា៖

«កំពុងចង់ដឹងការពិត ឃាត់ជាធ្វើអ្វី?!»

«ការពិតលើលោកនេះមានរាប់លានពេជ្រឯងជាតុលាការឬអី?! ដេកទៅជា» គេងាកមកបង្ខំសង្សារឱ្យឈប់និយាយ។

«ហេតុអ្វីសិស្សៗមិនរកយុត្តិធម៌ឱ្យគាត់ គាត់អាចត្រូវសិស្សៗខូចៗច្រានធ្លាក់ដឹង?!»

ភិនដាហាក់អាក់ដែរពេលឮពេជ្រមានយោបល់មកបែបនេះ។ ស្រាប់តែពេលនាងកំពុងនៅទីទើរសម្លឹងពេជ្រដោយកែវភ្នែកមុតថ្លា ឌីនគំហកតិចៗប្រឆាំងយោបល់របស់ពេជ្រ៖

«ប្រហែលមកពីគាត់ចេះដឹងរឿងគេខ្លាំងពេកទេដឹង?!»

«ប៉ុន្តែសម្រាប់ខ្ញុំវិញ ខ្ញុំគិតថាគាត់ឈឺឆ្អាលជាមួយសិស្សទេ គ្រាន់តែប៉ះពួកសិស្សខូចៗ»

«ខូចៗដូចពួកយើងអ៊ីចឹងនេះ!» ឌីនថាហើយក៏ឱបក្រសោបទាមទារថើបភិនដា ធ្វើឲ្យពេជ្រងាកមុខចេញ ទាំងមិនចង់ឃើញ។ ពេជ្របន្ទោសឌីន៖

«ពេលវេលានេះមិនសមលេងសើចអ៊ីចឹងទេឌីន!»

មើលពីក្រោយនិងស្តាប់សព្ទសូរពេជ្រនិយាយក៏អាចកាត់យល់បានថា គេហាក់កំពុងមិនសប្បាយចិត្តដែលខ្លួនឯកាឯឌីនមានស្រីស្អាតជាប់ទ្រូង។ ឌីនមិនអស់ចិត្តក៏និយាយឌឺដងឱ្យពេជ្រវិញ៖

«យើងមិនទាន់រកម៉ាលីឃើញមែន តែយើងក៏ដឹងថា ឯងជាមួយម៉ាលីទើបនឹងកសាងស្នេហាដែរវ៉ើយ!»

«ហើយ....កុំនិយាយប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់គេ!» ពេជ្រនិយាយហាក់កាន់តែមិនសប្បាយចិត្តនិងបែរមុខទៅសម្លឹងផ្លូវវិញ។

ឃើញដូច្នេះភិនដាក៏ច្រានដៃលដេញចេញហើយនិយាយខ្សឹបបន្ទោសៈ

«កុំលេងច្រើនពេក! តាមពិតទៅ ខ្ញុំមិនដែលគាំទ្រឲ្យពួកយើងធ្វើអ្វីៗខុសប្រពៃណីនោះទេ!»

ឌីនសើចក្អាកក្អាយចំអកឱ្យនាងៈ

«ស្អីគេ? ស្អីគេខុសប្រពៃណីហ្នឹង? ប្រពៃណីអ្នកណាបង្កើតឡើងមក? ស្លាប់អស់ហើយតាស់អ្វី? គ្រាន់តែមនុស្សស្រលាញ់គ្នាគឺខុសប្រពៃណីដែរ? លោក!!!»

នៅក្នុងសភាពបែបនេះឌីននៅតែសើចលេងព្ញៗកើតទៀត ធ្វើឲ្យនាងចេះតែនឹកឃើញទៅដល់កាយវិការមិនសមរម្យទាំងប៉ុន្មានដែលគេបានប៉ះពាល់លើរាងកាយរបស់នាង។

«បានហើយ! ឈប់និយាយ ហើយសម្ងំសម្រាកបន្តិចទៅ! តិចទៀតទៅមើលផ្លូវឲ្យពេជ្រម្តង!»

ទាំងពីរប្រាណស្ងប់ស្ងាត់ក៏ចាប់ផ្តើមលង់លក់ដោយមិនដឹងខ្លួនសន្សឹមៗទៅក្រោមទុក្ខសោកនិងភាពត្រជាក់ល្អកនៃស្បៃរាត្រីកាល។

ដាផ្អែករាងកាយទៅលើស្មាសង្សារ។

សំឡេងអ្វីមួយបានដាស់ធ្វើឲ្យស្រីស្អាតម្នាក់នេះភ្ញាក់ដឹងខ្លួនឡើងមកវិញយ៉ាងតក់ក្រហល់។

នោះគឺសម្រែកឲ្យជួយរបស់ឌីន....

«ពេជ្រ!»

ឌីនបញ្ចេញសំឡេងបានត្រឹមមួយម៉ាត់នេះគត់ដែលនាងបានឮ។

ស្រីស្អុះក្រោកឡើងស៊េងម៉េង ព្រោះប្រុសៗទាំងពីរនោះទៅណាបាត់ក៏មិនដឹង មិនឃើញពួកគេនៅក្នុងតូបនេះទៀតទេ ឃើញតែខ្លួនឯងអង្គុយស្ងៀមនៅក្នុងតូបយាម។ មេឃងងឹតដដែល។

ភិនដាមមិងមមាំងសម្លឹងទៅខាងក្រៅលើផ្លូវដែកចាស់។

មេឃពិតជាងងឹតពេកហើយ ដល់ថ្នាក់ទើបនឹងបើកភ្នែកឡើងក៏ដឹងថាងងឹតមើលអ្វីមិនឃើញ។

ប៉ុន្តែពេលនាងខំផ្ចង់ក៏ឃើញអ្វីម្យ៉ាងគួររន្ធត់។

ស្រីស្អុះក្រោកចេញទៅ ទីបំផុតក៏ដួលប្រួស។ ពេលផ្តើមស្រវេស្រវាក្រោក ដៃរាវប៉ះអ្វីមួយ។ វាគឺជាពិលធំរបស់ឌីន។ នាងអរណាស់ ប្រញាប់ប្រញាល់ បើកវាហើយបញ្ចាំងទៅគោលដៅ។

នៅទីនោះប្រមាណជា៨ទៅ១០ម៉ែត្រពីកន្លែងនាង ភិនដាពិតជាឃើញខ្មោចដែលត្រូវបានដាច់ជើងទាំងពីរដោយកាំបិតផ្គាក់ ហើយដេកស្លាប់ក្នុងថ្លុកឈាមទាំងកាំបិតដេកក្បែរនោះយ៉ាងកំណាចដូចគ្នា។ ករបស់គេក៏ត្រូវអារដូចគ្នានិងនីនឬរុធឬពូលក់ឧស។

ភិនដាទន់ជង្គង់ដួលគ្រឹបលើព្រះធរណីធ្វើឲ្យរបូតពិលពីដៃបញ្ចាំងទៅលើរូបរាងពេជ្រដែលកំពុងតែគេងផ្កាប់មុខដូចគ្នាប៉ុន្តែជើងគេនៅ។

នាងស្រែកខ្លាំងៗ ជួយផងៗៗៗជួយផងហេតុអីទៅ?

តែនាងស្រែកលែងចេញសំឡេងហើយ។

សូរសម្រិបជើងរត់មកពីចម្ងាយ។ ធុំក្លិនផ្សែងម៉ូតូ ស្នូរឡាន ......

ភីនដាទន្ទូរទន្ទេញសុំឱ្យជាអ្នកស្រុកមកដល់ទៅចុះ....រហូតដល់នាងសន្លប់បាត់ស្មារតី ប៉ុន្តែនាងនៅចាំបានថាអ្វីដែលនាងឮចុងក្រោយគឺសំឡេងរបស់អ្នកភូមិស្រែករន្ធត់។

«ពួកគេរកយើងឃើញហើយ!»

នាងគិតមុនពេលបិទភ្នែកសន្លប់....

---

ថ្ងៃនេះគឺជាថ្ងៃអាពាហ៍ពិពាហ៍បីឆ្នាំរបស់ពេជ្រហើយនិងភិនដា មនុស្សតែពីរនាក់គត់ដែលសំណាងមានជីវិតសល់ចុងក្រោយពីដំណើរកម្សាន្តដ៏គ្រោះថ្នាក់នៅឯតំបន់ចំណុចក្រហម។

តំបន់នោះត្រូវអាជ្ញាធរបិទចោលយូរហើយ។

មិត្តៗរបស់នាងរួមទាំងម៉ាលីបានត្រូវគេរកឃើញហើយធ្វើបុណ្យជាច្រើនឆ្នាំកន្លងមក ចម្លែកតែឃាតកៈនៅតែមិនមានដំណឹងឬតម្រុយអ្វី។ សពអ្នករងគ្រោះទាំងអស់មិនមូលទេ មានខ្លះដាច់ដៃ ខ្លះបាត់ជើង ចំណែកបបំពង់កត្រូវអារផ្តាច់ទាំងអស់។

ថ្ងៃនេះនាងចង់ទិញអ្វីម្យ៉ាងសំរាប់ប្តីសម្លាញ់របស់នាងដែរ ប៉ុន្តែមិនដឹងថាហេតុអ្វីបានជានាងទិញនាឡិកាដៃមួយជាកាដូគេ ស្រាប់តែមកដល់បន្ទប់ភិនដាក៏នឹកឃើញដល់នាឡិការបស់Gen ដែលខំសន្សំលុយទិញឱ្យហ៊ាង។

វាត្រូវបានរកឃើញនៅក្នុងព្រៃហេតុការណ៍កាលពី ជាង៧ឆ្នាំមុន។

ព្រឹត្តិការណ៍ចាស់ដែលបានបញ្ចាំងមកវិញនៅក្នុងអារម្មណ៍របស់ភិនដាមកទល់ពេលនេះ នាងមានវ័យចាស់ចិត្តគំនិតនឹងនរជាងមុន មិនងាយស្លន់ស្លោពិតមែន ប៉ុន្តែអ្វីម៉្យាងហាក់ដូចជាបុកទង្គិចបេះដូងនាង។

ឲ្យតែនាងនឹកឃើញដល់ម៉ាលី ឌីន និងមិត្តភក្តិបួននាក់ទៀត ទោះបីថាសេចក្តីស្នេហាកាលពីយុវវ័យរវាងនាងនិងឌីនបានក្លាយទៅជាពពករសាត់បាត់តាមភ្លៀងទៅហើយមែន ទោះពេលនេះចិត្តនាងមានតែពេជ្រដែលជាប្តីឆ្លងកាត់គ្រោះថ្នាក់មកជាមួយគ្នាប៉ុន្តែមិនដឹងជាហេតុអីយប់នេះ អារម្មណ៍ចម្លែកមួយដឹកនាំនាងទៅរករឿងចាស់។

នាងដាក់កាដូនាឡិកាទុកទៅលើគ្រែ ហើយចេញមករកងូតទឹក។ កំពុងផ្ចង់ភ្នែកសម្រាកក្នុងពពុះសាប៊ូព្រោះចង់សម្រាលភាពធ្ងន់នៃឌីប្រេសិនកប់ក្នុងជម្រៅចិត្ត សត្វកណ្តុរមួយបានពាំអ្វីចេញមកពីទីណាមិនដឹងជាសំណុំក្រដាសហើយរត់កាត់នាង។

នាងគប់វានឹងដុំសាប៊ូ ព្រោះខ្លាចថានោះជាឯកសារសំខាន់។

កណ្តុរទៅបាត់សល់នូវរូបថតប៉ុន្មានសន្លឹក។

នាងក្រោកកន្សែងមករុំហើយរើសអ្វីៗទាំងនោះពិនិត្យ។

រៀបការជាមួយពេជ្របានបីឆ្នាំហើយ មិនដែលដឹងទេថាគេធ្លាប់រៀនគរុកោសល្យ?

ក្រៅពីសញ្ញាបត្រទាំងនេះ ថែមទាំងមានរូបថតដែលមានគ្រូធីមទៀត?

អ្វីមួយប្លែកៗលេចមករញ្ជោចឡើងក្នុងចិត្តនាង។

នាងចាប់ផ្តើមស្រាវស្រាវាពិនិត្យឯកសារផ្សេងៗទៀត។

---

យប់នោះ.....

«ពួកយើងរៀបការបីឆ្នាំហើយអត់ទាន់មានកូនសោះ អូនយល់ថាម៉េចដែរប្រពន្ធសម្លាញ់?!»

«គឺចង់បានខ្លាំងណាស់ តែនៅតែត្រូវអត់ធ្មត់រង់ចាំ!»

នាងនិយាយតបប្តីធម្មតាៗតែមិនបែរខ្នងទៅទេទុកឲ្យពេជ្រឱបពីក្រោយខ្លួនគេថើបកញ្ចឹងកនិងអង្អែលចង្កេះនាងដូចរាល់ដង។

«អូខេ បងតែងតែរង់ចាំបានជានិច្ចយូរឆ្នាំប៉ុនណាក៏ដោយ!»

ដៃរបស់គេបង្អូសមកអង្អែលលើកំភួនដៃរបស់នាងបង្ហាញសញ្ញាថាគេចង់ប្រលោមថ្នាក់ថ្នមនាងទៀតហើយ។ ទោះបីយ៉ាងណានាងហាក់គ្មានអារម្មណ៍ទេព្រោះជាប់គិតទៅដល់រឿងជាច្រើនមិនជាក់លាក់។

ទីបំផុតនាងដាច់ចិត្តសួរតិចៗ៖

«ហេតុអីបានជាបងសម្លាប់គ្នាយើងទាំង៦នាក់នោះ? ហើយអ្នកលក់ឪសម្នាក់នោះទៀត?»

ដៃពេជ្រឈប់ទ្រឹងលើខ្លួនរបស់នាង។

គេមិនមាត់មិនក ដង្ហើមរបស់គេក៏ឈប់បង្ហាញនូវភាពស្រើបស្រាលដែរ បែរជាដកញាប់ដោយកំហឹង។

«បងជាគ្រូធីមម្នាក់នោះ! បើមានវាសនានៅរស់ហេតុអ្វីមិនវិលមកសាងល្អ?!»

ពេជ្រនៅតែមិនឆ្លើយនឹងពាក្យប្រពន្ធ នាងក៏និយាយបន្ថែមទាំងមិនបែរខ្នង។

«ព្រោះយប់នោះបងតាមដានឃើញពួកគេមានស្នេហាលួចលាក់ ក៏ត្រូវពួកគេព្រួតវាយធ្លាក់ទឹក? ក្រោយមកពេលបងត្រូវគេសង្គ្រោះជីវិតក៏មកកើតជាគំនុំសម្ងំរកវិធីមកសងសឹកជាមួយពួកគេ? តែហេតុអ្វីចាំបាច់ឃោរឃៅកាត់បំពង់កពួកគេ? ហើយឪនវិញ! បងសម្លាប់ឪនព្រោះចង់បានខ្ញុំឬមួយយ៉ាងម៉េច?! ថ្ងៃណាបងសម្លាប់ខ្ញុំម្នាក់ទៀត? ហើយចំណែកម៉ាលី ពេលនោះក្រែងបងមាននាងហើយហេតុអ្វីសម្លាប់នាង?»

ស្អែកឡើងប៉ូលិសបានរកឃើញពីរនាក់ប្តីប្រពន្ធនេះស្លាប់ដោយថ្នាំបំពុលនិងគេងឱបគ្នាលើគ្រែរបស់ពួកគេនៅចំថ្ងៃខួបអាពាហ៍ពិពាហ៍។ នៅទីនោះមានបន្សល់សំបុត្រមួយរបស់ពេជ្រ៖

«ក្មេងទំនើងអស់នេះបានចាក់ខ្ញុំនិងអារបំពង់កខ្ញុំ ឆូតមុខខ្ញុំ ច្រានខ្ញុំទម្លាក់ទឹក ថែមទាំងប្រើបុណ្យសក្តិប៉ាម៉ាក់គេ បំបិទរឿងនេះចោល! ខ្ញុំបានកែមុខមាត់ ចង់រស់ក្នុងជីវិតថ្មីដែរ តែម៉ាលីនាងជាងមនុស្សស្រីសាវ៉ា! មានស្នេហាជាមួយខ្ញុំ សន្យាថាស្មោះជាមួយខ្ញុំ តែបែរលបលួចមានស្នេហាស្ងាត់ៗក្នុងព្រៃពីរនាក់អាឪន ដែលមានសង្សារមកដែរ! មនុស្សពួកនេះរស់នៅនាំតែធ្ងន់ផែនដីទេ! មនុស្សកម្សត់ដូចខ្ញុំម្នាក់ទៀតដែរគឺភិនដា ប្រពន្ធរបស់ខ្ញុំមិនដែលដឹងថា គ្រប់គ្នាក្បត់ចិត្តនាងឡើយ! ខ្ញុំនាំនាងចេញទៅហើយ មិនឱ្យពិភពលោកនេះកុហកនាងទៀតនោះទេ!» **ចប់**